**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ២៤៩
ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៣
សាលដីកា
លេខ: ១៩៧
ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................ ជាចៅក្រម
៦-លោក ............... ជាចៅក្រម
៧-លោក ................. ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក .............. ជាចៅក្រម

ក្រឡាបញ្ជី

-លោក ................

តំណាងមហាអយ្យការ

-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ២២៣(ឈ)ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះ ឡសហ( ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ថ្នាំពេទ្យ ទីលំនៅផ្ទះលេខ ២៤៩CEc+E ក្រុមទី២០ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវីលោក ..............

ចុងចម្លើយឈ្មោះ បហ(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១០១០ ផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌទូលគោក ក្រុងភ្នំពេញ ។

មានលោក ...........មេធាវីការពារ និងជាតំណាង .

កម្មវត្ថុបណ្តឹ: ប្តឹងទាមទារប្រាក់ .

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៨៧ ចុះថ្ងៃទី១១ ខែកុម្ភៈឆ្នាំ២០០៣ របស់ឈ្មោះប៊ុន ហួ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ ២២៣(ឈ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៣-៨-១៩៩៧របស់ដើមចោទឈ្មោះឡេង សុងហេង បញ្ជាក់ថា ខ្លួនប្តឹងទារប្រាក់ថ្លៃទិញផ្ទះពីចុងចម្លើយឈ្មោះប៊ុន ហូ ចំនួន៣៩.៥០០ដុល្លាអាមេរិក និងជម្ងឺចិត្ត ចំនួន៩.០០០ដុល្លាអាមេរិក ដោយមូលហេតុថាខ្លួនបានទិញផ្ទះពីឈ្មោះប៊ុន ហូ ក្នុងតម្លៃដូចខាងលើ ហើយបានធ្វើកិច្ចសន្យាជានាខុសត្រូវសព្វបែបយ៉ាងចំពោះបាតុភាពដែលកើតឡើង ។ ក្រោយពី ខ្លួនចូលស្នាក់នៅមិនបានប៉ុន្មានខែផង ស្រាប់តែមានដំណឹងថា ឈ្មោះប៊ុន ហូ បានយកផ្ទះពាក់ព័ន្ធមកលក់ឱ្យខ្លួន ហើយថ្មីៗនេះ សាលដីការបស់តុលាការកំពូលបានសម្រេចចូលជាស្ថាពរប្រគល់ផ្ទះ ដែលខ្លួនបានទិញពីឈ្មោះប៊ុន ហូ ទៅឱ្យឈ្មោះលឹម សុខ ជាម្ចាស់កម្មសិទ្ធិទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣១(ក) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៨៧របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៣-៣-៩៧ របស់ដើមចោទឈ្មោះឡេងសុងហេង ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ទទួលពាក្យសុំពឹងពាក់មេធាវីចុះថ្ងៃទី០៤-៩-៩៥ របស់ឈ្មោះប៊ុន ហូ ឱ្យទៅមេធាវីចុង អៀវហេង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-បង្គាប់ឱ្យឈ្មោះប៊ុន ហូ សងប្រាក់ចំនួន៣៩.៥០០ដុល្លាអាមេរិក ជម្ងឺចិត្ត៣.០០០ដុល្លាអាមេរិក ឱ្យឈ្មោះឡេង សុងហេង វិញ ចាប់ពីថ្ងៃនេះតទៅ ។

៤-ករណីឈ្មោះប៊ុន ហួ រឹងទទឹងពុំព្រមសងប្រាក់គ្រប់ចំនួនឱ្យទៅឈ្មោះឡេងសុងហេងទេ សម្រេចរឹបអូសទ្រព្យសម្បត្តិ និងដាក់គុកលើរូបកាយតាមមាត្រា១៣៣ នៃច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-បង្គាប់ឱ្យឈ្មោះប៊ុន ហូ បង់ប្រាក់ប្រដាប់ក្តី៧០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្មឹងចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ ប្រាក់នេះ បានកាត់យកពីប្រាក់៥០០០៛ ដែលដើមចោទបានបង់ទុករួចស្រេច ។

កាលបើហួសឧទ្ធរណ៍ហើយ បង្គាប់ឱ្យឈ្មោះប៊ុន ហួ សងប្រាក់៧០០០៛ ទៅឱ្យដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ១%លើប្រាក់ដើម និងប្រាក់ជម្ងឺចិត្ត ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន៨០% ព្រមទាំងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៦-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ បើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៨៩(ក)ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះប៊ុន ហួ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៣១(ក)ចុះថ្ងៃទី២២-១០-៩៧ របស់តុលាកាក្រុងភ្នំពេញត្រង់ចំណុចសាលក្រមទាំងមូល

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣(ក) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានអ្វីមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះប៊ុន ហួ ចុះថ្ងៃទី០៦-១១-៩៥ ទុកជាត្រឹមត្រូវតាមច្បាប់តែគប្បីបដិសេធបោលដោយខុសនិងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៣១(ក)ចុះថ្ងៃទី២៦-១៦-៩៧ ទុកជាបានការពេញទាំងមូល ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគីសម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៦(ក) ចុះថ្ងៃទី១១ ខែមិនាឆ្នាំ១៩៩៨ របស់ឈ្មោះចុង អៀវហេង ជាមេធាវីតំណាងឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៣(ក)ចុះថ្ងៃទី១៨ខែកម្ភៈឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៦(ក)ចុះថ្ងៃទី១១-០៣-១៩៩៨ របស់លោក ចុង អៀវហេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៣ (ក) ចុះថ្ងៃទី១៨-០២-១៩៩៨ របស់តុលាការក្រុងភ្នំពេញ បោលជាអសារបង់ ដោយឱ្យឈ្មោះប៊ុន ហួ រួចផុតពីការប្តឹងទាមទារ ប្រាក់ថ្លៃលក់ផ្ទះនេះ ។ ៳

៣-រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ រួចហើយ គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣០០០៛។

កាលបើហួសបណ្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះឡេង សុងហេង សងប្រាក់១៣.០០០៛ ឱ្យទៅដើមបណ្តឹងឧទ្ធរណ៍វិញ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៥១ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះឡេង សុងហេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤០ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៥៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះឡេង សុងហេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣០២ ចុះថ្ងៃទី១៤-១០-១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលឈ្មោះឡេង សុងហេង បានបង់គឺៈ

-ពន្ធចុះបញ្ជីក្តីនឹងពន្ធហ៊ឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោកប៊ុន ហួ សងប្រាក់ចំនួន១៩.០០០៛ នេះទៅឱ្យលោកឡេង សុងហេង វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២១(ឈ) ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះរឿងរដ្ឋប្បវេណីលេខ៣៨ ចុះថ្ងៃទី០៥-០៦-២០០២ របស់សាលាឧទ្ធរណ៍សារជាថ្មីឡើងវិញ តាមសាលដីការដ្ឋប្បវេណីលេខ៤០ ចុះថ្ងៃទី២៥ ខែកុម្ភៈឆ្នាំ២០០២ របស់តុលាការកំពូល ។

២-ទទួលស្គាល់ពាក្យសុំពឹងពាក់មេធាវីចុះថ្ងៃទី២២-០៤-២០០២ របស់លោក មេធាវីគី តិច ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ១៣១(ក)ចុះថ្ងៃទី២២-១០-១៩៩៧ និងសាលក្រមរដ្ឋប្បវេណីចំពោះមុខលេខ១៣(ក)ទុះថ្ងៃទី១៨-០២-១៩៩៨ របស់តុលាការ ក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងលើអាជ្ញាធរតុលាការ៥០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឡេង សុងហេង ចំពោះមុខមេធាវីការពារឱ្យដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១៣៨ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះ ប៊ុន ហួ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១២១(ឈ) ចុះថ្ងៃទី២៣ខែកក្កដាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២២៣(ឈ)ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងទាស់ចុះថ្ងៃទី០៤-០៩-២០០២របស់ឈ្មោះប៊ុនហួ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-កម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២១(ឈ)កក្កដាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ មេធាវីការពារឱ្យដើមចោទ(ម៉ង់ ងីម ឡេង សុងហេង) កំបាំងមុខចុងចម្លើយ ប៊ុន ហួ តែទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លខ៨៧ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ ឈ្មោះប៊ុន ហួ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២២៣(ឈ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៣២ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈរឿងនេះជារឿងវិវាទប្តឹងទាមទារប្រាក់សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះឡេង សុងហេង នាពេលសវនាការថាៈ ពីដំបូងខ្លួនប្តឹង ទាមទារយកផ្ទះ តុលាការមិនព្រមសម្រេចឱ្យផ្ទះខ្លួនទេ ទើបខ្លួនបានប្តឹងយកលុយពី ប៊ុន ហួ វិញព្រោះខ្លួនយល់ថា ខ្លួនមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្តឹងទាមទារប្រាក់ ព្រោះខ្លួនទិញផ្ទះនេះពីប៊ុន ហួ ខ្លួនមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្តឹងទារលុយពីប៊ុន ហួ ដែរ ។ សាលាឧទ្ធរណ៍បានសម្រេចដកហូតផ្ទះខ្លួនហើយ ខ្លួនបានសម្រេចប្តឹងទាមទារប្រាក់ពី ប៊ុន ហួ ព្រោះវាជាសិទ្ធិរបស់ខ្លួន ។ លោកលឹមសុខ គាត់ឈ្មះក្តីពុំទាន់អនុវត្តសាលក្រមយកផ្ទះនេះទេ។ មូលហេតុខ្លួនបានអង្វរករគាត់កុំឱ្យអនុវត្ត ដោយខ្លួនសុខចិត្តទិញផ្ទះនេះពីឈ្មោះ លឹម សុខ វិញ ភក់ប្រាក់មួយចំនួនឱ្យគាត់ លោកលឹម សុខ ក៏យល់ព្រមរង់ចាំខ្លួនបង់លុយបង្គ្រប់ នៅពេលដែលខ្លួនទារលុយបានពីឈ្មោះប៊ុន ហួ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកប៉ិច វិច្ឆិកា ជាមេធាវីការពារ និងតំណាងឱ្យចុងចម្លើយ បានលើកឡើងថា តាមការសិក្សារបស់ខ្លួនឃើញថា ក្នុងរឿងនេះ គឺជាការទិញលក់ផ្ទះ ផ្ទះនេះដំបូងជាផ្ទះរបស់ឈ្មោះលឹម ម៉ាប់ ក្រោយពីការសាងសង់រួច បានខ្វះលុយមួយចំនួន គាត់បានទៅជាវគ្រឿងសំណង់ពីឈ្មោះលឹម សុខ មានការជំពាក់៥ម៉ឺនដុល្លាអាមេរិក បន្ទាប់មកគាត់បានធ្វើ លិខិតមួយឱ្យទៅឈ្មោះលឹម សុខ ដើម្បីឱ្យលិម សុខ ជឿ និងទុកចិត្តថា គាត់ដាក់ធានាសំណង។ ក្រោយមកគាត់បានលក់ផ្ទះនេះមកឱ្យកូនក្តីខ្លួនឈ្មោះប៊ុន ហួ ហើយកូនក្តីរបស់ខ្លួនបានលក់ផ្ទះនេះទៅឱ្យឈ្មោះឡុសហ បន្តទៀត ។ កូនក្តីខ្លួនទិញផ្ទះនេះមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ មានសុរិយោដីក្រុងជឹងឮ នៅពេលដែលលឹម សុខ ប្តឹងទាមទារយកផ្ទះនេះ មិនត្រឹមត្រូវតាមច្បាប់ ឡើយ គឺកើតចេញពីការជំពាក់ប្រាក់ជៀវគ្រឿងសំណង់ ។ ការដែលសាលាឧទ្ធរណ៍សម្រេចតាម សាលដីកាលេខ៦១៦,៦១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ បានសម្រេចឱ្យកូនក្តីខ្លួនរួចផុតពី ការសងប្រាក់ទៅឱ្យឈ្មោះឡេង សុងហេង និងម៉ង់មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក.............ជាមេធាវីការពារឱ្យដើមចោទបានលើកឡើងថាៈ ពាក់ព័ន្ធទៅនឹងការទិញលក់នេះ ខ្លួនសូមជម្រាបថា បញ្ហានេះ គឺជាកាតព្វកិច្ចអ្នកលក់ មិនមែនកាតព្វកិច្ចត្រឹមតែធ្វើលិខិតស្នាមឱ្យ

បានត្រឹមត្រូវតាមច្បាប់ទេ កាតព្វកិច្ចរបស់អ្នកលក់ ត្រូវតែមានវត្ថុដែលលក់ជារបស់ខ្លួនពិតៗ ហើយវត្ថុនោះត្រូវតែមានវិការៈទាំងឡាយដែលពាក់ព័ន្ធទៅនិងវត្ថុ ។ ហើយក្រឹត្យច្បាប់លេខ៣៨ ត្រង់មាត្រា៤៣,៤៦,៤៩ បានបញ្ជាក់ច្បាស់ហើយថា វត្ថុនោះការទិញលក់ច្រើនគ្នា ហើយវត្ថុនោះត្រូវតុលាការដកហូតឱ្យអ្នកណាមួយនោះ គឺអ្នកនោះត្រូវ មានកាតព្វកិច្ចធានា ។ ម៉្យាងទៀតកូនក្តីខ្លួនមានសិទ្ធិមួយទៀតផ្អែកលើមាត្រា២២ នៃក្រឹត្យច្បាប់លេខ ៣៨ កូនក្តីខ្លួនក៏មានសិទ្ធិប្តឹងពីអ្នកលក់បាន ដូច្នេះកូនក្តីខ្លួនមានសិទ្ធិប្តឹងទាមទារប្រាក់ពីលោក ប៊ុន ហួ វិញដែរ ។ ការដែលតុលាការកំពូលបង្វិលសំណុំរឿងឱ្យទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះ ជាលើកទី២ មានលក្ខណៈត្រឹមត្រូវហើយ ។ ក្នុងនាមខ្លួនជាមេធាវីការពារឱ្យឈ្មោះឡេង សុងហេង ខ្លួនសំណូមពរតម្កល់សាលដីការដ្ឋប្បវេណីលេខ២២៣(ឈ)ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

-ក្រោយពីបានស្តាប់បាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយលោកឡេង សុងហេងនិងសេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៧ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកប៊ុន ហួ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តីនិងមាត្រា២២៦នៃនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីបានផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យឈ្មោះប៊ុន ហួ សងប្រាក់ថ្លៃផ្ទះចំនួន៣៩៥០០ដុល្លាអាមេរិក ទៅឱ្យលោកឡាង សុងហេង ទាំងស្រុងនោះជាការពុំត្រឹមត្រូវទេ ដោយហេតុថា :

+ លោកឡាង សុងហេង ក្នុងឋានៈជាម្ចាស់កម្មសិទ្ធិនៃផ្ទះទំនាស់ និងជាម្ចាស់បណ្តឹង ឧទ្ធរណ៍បានចូលរួមជាភាគីនៃរឿងក្តីលេខ៣៨៩ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៥ របស់តុលាការ ក្រុងភ្នំពេញរួចហើយ ហើយមិនបានប្តឹងសាទុក្ខឡើយ ធ្វើឱ្យសាលក្រមក្នុងរឿងក្តីនោះបានចូលស្ថាពរ ដូចនេះចាត់ថា ភាគីលោកឡេង សុងហេង មានកំហុស ។

+ រីឯលោក ប៊ុន ហួ ក៏ត្រូវបានតុលាការក្រុងភ្នំពេញ បញ្ចូលជាតតិយជននៃរឿងក្តីលេខ៣៨៩ ចុះថ្ងៃទី០៣ខែកក្កដា ឆ្នាំ១៩៩៥ ដែរ ប៉ុន្តែមានការធ្វេសប្រហែសមិនបានប្រើសិទ្ធិរបស់ខ្លួន តាមផ្លូវច្បាប់ចូលរួមក្នុងនីតិវិធីរបស់តុលាការឡើយ ដោយមិនបានប្តឹងឧទ្ធរណ៍ ដែលអំពើនេះចាត់ថា លោកប៊ុន ហួ ក៏មានកំហុសផងដែរ ។

- យល់ឃើញថា គូភាគីមានកំហុសដូចគ្នា ដូចនេះត្រូវមានកាតព្វកិច្ចសាមគ្គីភាពក្នុងការទទួលខុសត្រូវលើការខូចខាតដែលភាគីនីមួយៗត្រូវទទួលរង ។

- យល់ឃើញថា លោកប៊ុន ហួ មិនបានចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវីរបស់លោកបានចូលរួម ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២២៣(ឈ)ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ និងមេធាវីគូក្តី**

**កំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ៨៧ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកប៊ុនហួ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ឯគតិច្បាប់ត្រូវខ្លះ ខុសខ្លះ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២២៣(ឈ) ចុះថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្គាប់ឲ្យលោក ប៊ុន ហួ សងប្រាក់ចំនួន១៩.៧៥០ដុល្លា ឲ្យទៅលោកឡេង សុងហេង ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលដើមចោទ បានបង់នៅតុលាការកំពូលគឺ

-ពន្ធចុះបញ្ជីក្តីនឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

-បង្គាប់ឱ្យលោកប៊ុន ហួ បង់ពន្ធសមាមាត្រចំនួន១%លើប្រាក់ដែលត្រូវសង ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៣ខែកក្កដា ឆ្នាំ២០០៦ ។